

Kids of Destiny®
www.kidsofdestiny.org

Kids of Destiny®
Reaching the Next Generation

## 2.05 លោកយ៉ូសែប និងបងប្អូនរបស់គាត់នៅស្រុកអេស៊ីព្ទ

លោកយ៉ូសែបត្រូវបានតែងតាំង ជាអ្នកគ្រប់គ្រងលើស្រុកអេស៊ីព្ទទាំងមូល។ គាត់ទទួលបន្ទុកគ្រប់គ្រងភោគផលទាំងអស់ដែលអាចដាំដុះទទួលផលបាន ក្នុងអំឡុងពេលប្រាំពីរឆ្នាំនៃភោគផលដំណាំល្អ ។ ដោយសារគាត់គ្រប់គ្រងផលដំណាំបានល្អ ស្បៀងអាហារជាច្រើនត្រូវបានផ្ទុកសម្រាប់ឆ្នាំដែលមិនអាចធ្វើការដាំដំណាំបាន មានប្រជាជនមកពីប្រទេសផ្សេងៗជាច្រើននាំគ្នាមកស្នើសុំអាហារ។ លោកយ៉ូសែបអាចជួយពួកគេបានដោយ សារគាត់បានជឿទុកចិត្តលើព្រះ ហើយបានរៀបចំផែនការយ៉ាងល្អសម្រាប់ពេលនោះ។ នៅពេលលោកយ៉ាកុបដែលជាឪពុករបស់យ៉ូសែបបានលឺថា មានស្បៀងអាហារនៅស្រុកអេស៊ីព្ទ លោកបានប្រាប់កូនប្រុសរបស់លោកឲ្យចាកចេញពីផ្ទះនៅស្រុកកាណាន ហើយទៅទិញស្បៀងអាហារនៅស្រុកអេស៊ីព្ទ ។ បងៗទាំងដប់បានទៅស្រុកអេស៊ីព្ទ ឯប្អូនពៅ បេនយ៉ាមីននៅផ្ទះ។ ពេលបងប្អូនបានមកដល់ ហើយសុំទិញស្បៀង លោកយ៉ូសែបបានឃើញហើយដឹងថា ទាំងនេះជាបងប្អូនរបស់គាត់ ។ ប៉ុន្តែបងប្អូនគាត់មិនបានដឹងថាបុរសនេះ គឺយ៉ូសែបជាប្អូនរបស់ពួកគេទេ ។ បន្ទាប់មកយ៉ូសែបបានសួរសំណួរជាច្រើនដល់ពួកគេ ។ ពួកគេបានសារភាពចំពោះគាត់ថា ពួកគេមានប្អូនប្រុសម្នាក់ ហើយពួកគេមានប្អូនប្រុសម្នាក់ទៀតដែរ ប៉ុន្តែប្អូនគេម្នាក់នោះ (យ៉ូសែប) មិនបាននៅជាមួយពួកគេទៀតទេ ។ លោកយ៉ូសែបបាននិយាយថា "សូមបង្ហាញខ្ញុំថាអ្នកជាមនុស្សស្មោះត្រង់ ។ ត្រឡប់ទៅផ្ទះវិញ ហើយនាំប្អូនប្រុសពៅរបស់អ្នកមក។ បងៗបានត្រឡប់ទៅផ្ទះវិញ ហើយទៅជួបលោកយ៉ាកុបដែលជាឪពុករបស់ពួកគេ។ ពួកគេបានប្រាប់គាត់ថាពួកគេត្រូវបានស្នើសុំ ឲ្យនាំបេនយ៉ាមីនត្រឡប់មកស្រុកអេស៊ីបជាមួយ។ លោកយ៉ាកុបពិបាកចិត្តខ្លាំងមែនទែន។ គាត់ខ្លាចថាគាត់នឹងបាត់បង់បេនយ៉ាមីនដូចដែលគាត់បានបាត់បង់យ៉ូសែបដែរ។ ទោះជាយ៉ាងណាគាត់បានឲ្យបេនយ៉ាមីនទៅ ព្រោះគ្រួសារគាត់ប្រាកដជាស្លាប់ដោយគ្មានអាហារបរិភោគជាមិនខាន។ នៅពេលដែលបងប្អូនទាំងអស់គ្នាទៅដល់ស្រុកអេស៊ីព្ទ ហើយគេបានទៅជួបលោកយ៉ូសែប ពួកគេមានការភ្ញាក់ផ្អើល និងភ័យខ្លាចជាខ្លាំង។ លោកយ៉ូសែបបានស្នើឲ្យ ទាំងអស់គ្នាទៅផ្ទះរបស់លោកផ្ទាល់។ ពួកគេភ័យខ្លាចថា ពួកគេមិនបានធ្វើឲ្យលោកយ៉ូសែបពេញចិត្ត។ ពួកគេគ្មានជម្រើសអ្វីផ្សេងក្រៅពីទៅនោះទេ។ លោកយ៉ូសែបបានរៀបចំពិធីជប់លៀងដ៏ធំមួយសម្រាប់ពួកគេ ។ គាត់បានប្រាប់ពួកគេ កុំឲ្យបារម្ភឡើយ ហើយប្រាប់ថា៖ «សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្ត» បងបងគាត់ក៏បានក្រាបថ្វាយបង្គំលោក ហើយបានជូនអំណោយដែលលោកយ៉ាកុបបានផ្ញើមក ។ លោកយ៉ូសែបក៏ចាប់ផ្តើមសួរសំណួរទៀត ។ យ៉ូសែបបានសួរថា៖ «តើឪពុកអ្នកសុខសប្បាយជាទេ? "ហើយតើនេះជាប្អូនពៅដែលអ្នកបានប្រាប់យើងនោះមែនទេ?" បន្ទាប់មក គាត់បានទៅបន្ទប់មួយហើយយំខ្សឹកខ្សួល ដោយសារតែបានជួបបងប្អូនរបស់គាត់វិញ បន្ទាប់ពីនោះមក គាត់បានរៀបចំផែនការមួយ។ គាត់បានឲ្យអ្នកបម្រើរបស់គាត់ដាក់ពែងប្រាក់មួយនៅក្នុងកាបូបស្ពាយបេនយ៉ាមីនដោយសម្ងាត់ ។ ក្រោយមកគាត់នឹងចោទប្រកាន់បងប្អូនគាត់ថាបានលួចរបស់របរ នៅពេលដែលពួកគេកំពុងតែចាកចេញ វិលត្រឡប់ទៅផ្ទះវិញ ។ តើអ្នកណាបានលួចយកពែងរបស់ខ្ញុំ? យ៉ូសែបបានសួរ អ្នកណាដែលបានលួចវានឹងត្រូវនៅ ស្រុកអេស៊ីព្ទធ្វើជាទាសកររបស់ខ្ញុំ។ បងប្អូនលោកយ៉ូសែបភ័យខ្លាចខ្លាំងមែនទែននៅពេលដែលគេរកឃើញពែងនៅបេនយ៉ាមីន។ បងប្រុសម្នាក់ឈ្មោះយូដាបានពោលថា៖ «សូមកុំចាប់បេនយ៉ាមីន ជាទាសកររបស់អ្នកឡើយ។ សូមឱ្យយកខ្ញុំជំនួសគាត់ទៅ ឪពុករបស់យើងចាស់ហើយ គាត់ច្បាស់ជាស្លាប់ប្រសិនបើបេនយ៉ាមីនមិនបានវិលត្រឡប់ទៅជួបគាត់វិញ។ លោកយ៉ូសែបមិនអាចលាក់បាំងថា គាត់ជានរណាពីពួកគេទៀតបានទេ ។ គាត់បានប្រាប់ពួកគេថាគាត់គឺជាប្អូនប្រុសរបស់ពួកគេគឺយ៉ូសែប ។ គាត់បាននិយាយថា "កុំមានអារម្មណ៍មិនល្អអី ព្រោះអ្នកបានលក់ខ្ញុំឱ្យឈ្មួញអេហ្ស៊ីព្ទតាំងពីយូរណាស់ហើយនោះអី ព្រះអម្ចាស់មានផែនការឲ្យខ្ញុំនៅទីនេះ ហើយអាចជួយសង្គ្រោះអ្នកទាំងអស់គ្នាក្នុងពេលទុរ្ភិក្សនេះ។ ត្រលប់ទៅផ្ទះវិញហើយយកឪពុកនិងក្រុមគ្រួសាររបស់យើងទាំងមូលមក។ នាំយកទាំងសត្វរបស់អ្នកទាំងអស់មកផង។ ខ្ញុំនឹងរកកន្លែងពិសេសណាមួយសម្រាប់បងៗ ដើម្បីឲ្យរស់នៅពេញមួយជីវិតតែម្តង។ បន្ទាប់មកយ៉ូសែបបានឲ្យអំណោយជាច្រើនដល់ពួកគេ ។ ពួកគេបានត្រឡប់ទៅស្រុកកាណានវិញ ហើយបានប្រាប់ឪពុករបស់ពួកគេថាយ៉ូសែបនៅរស់ ហើយបានគ្រប់គ្រងលើស្រុកអេស៊ីបផងដែរ ។ ចិត្តរបស់លោកយ៉ាកុបពិតជារីករាយណាស់ ។ លោកយ៉ាកុបមានប្រសាសន៍ថា៖ «សមល្មមហើយ ដែលកូនប្រុសខ្ញុំនៅមានជីវិតរស់ ខ្ញុំនឹងទៅជួបគាត់ម្តងទៀតមុននឹងខ្ញុំស្លាប់» ។ **លោកុប្បត្តិជំពូក ៤២-៤៥**

2.05 **បងប្អូនលោកយ៉ូសែបនៅស្រុកអេស៊ីព្ទ សេចក្ដីណែនាំសម្រាប់គ្រូបង្រៀន**

**កំណត់សម្គាល់៖**

1. លោកយ៉ូសែបជាអ្នកគ្រប់គ្រងលើស្រុកអេស៊ីព្ទ រយៈពេល៧ឆ្នាំនៃភោគផលល្អ លោកបានផ្ទុកស្បៀងគ្រប់គ្រាន់ត្រៀមសម្រាប់៧ឆ្នាំក្រោយដែលមិនមានដំណាំអាចដាំបាន ។ មនុស្សម្នាមកពីគ្រប់ទិសទីមកទិញស្បៀងពីលោកយ៉ូសែប ។
2. ឪពុករបស់លោកយ៉ូសែប គឺលោកយ៉ាកុប និងបងប្អូនរបស់គាត់រស់នៅស្រុកកាណាន ។ ពួកគេត្រូវការស្បៀងដែរ ដូចនេះលោកយ៉ាកុបបានបញ្ជូនកូនៗដប់នាក់ ទៅទិញស្បៀងនៅស្រុកអេស៊ីព្ទ ។
3. លោកយ៉ូសែបបានប្រាប់ទៅបងៗរបស់គាត់ថា បើពួកគេពិតជាមនុស្សស្មោះត្រង់មែន សុំទៅយកប្អូនពៅរបស់ពួកគេ គឺបេនយ៉ាមីនមកស្រុកអេស៊ីបមក ។ លោកយ៉ូសែបដឹងថាពួកគេ ជាបងបងរបស់គាត់ ។ តែពួកគេមិនដឹងថាបុរសនោះ ជាប្អូនរបស់ពួកគេ គឺជាលោកយ៉ូសែបទេ ។
4. ពេលដែលបេនយ៉ាមីនមកដល់ស្រុកអេស៊ីព្ទ លោកយ៉ូសែបបានលាក់ពែងប្រាក់មួយនៅក្នុងសម្ពាយរបស់ បេនយ៉ាមីន ដូចនេះគាត់មានហេតុផលក្នុងការចោទប្រកាន់ពួកគេពីបទ លួចទ្រព្យ ហើយយ៉ូសែបអាចឃាត់បេនយ៉ាមីនទុកជាទាសករ ។
5. ម្នាក់ក្នុងចំណោមបងបងគាត់គឺលោកយូដា បានទាមទារឲ្យយ៉ូសែបយកគាត់ជាទាសករជំនួសបេនយ៉ាមីន។
6. ក្រោយមកយ៉ូសែបក៏ប្រាប់ពួកគេថា គាត់គឺយ៉ូសែបប្អូនរបស់ពួកគេ ។ លោកបានប្រាប់ពួកគេឲ្យទៅស្រុកយកឪពុក និងគ្រួសារទាំងអស់មកស្រុកអេស៊ីព្ទមក ព្រមទាំងសត្វរបស់ពួកគេផងដែរ ។ លោកនឹងរកកន្លែងល្អមួយសម្រាប់ទាំងអស់គ្នារស់នៅ ។

**សំណួរ**

១) តើក្នុងនាមជាអ្នកគ្រប់គ្រងលើស្រុកអេស៊ីព្ទ គាត់មានភារកិច្ចធ្វើអ្វី ?

២) តើលោកយ៉ាកុបបានធ្វើដូចម្ដេចនៅពេលដែល គ្រួសារគាត់ត្រូវការស្បៀងអាហារ ?

៣) តើលោកយ៉ូសែបឲ្យពួកគេទៅស្រុកយកនរណាមកអេស៊ីព្ទវិញ ?

៤) តើលោកយ៉ូសែបធ្វើដូចម្ដេច ទើបអាចរកលេសចាប់បេនយ៉ាមីនជាទាសករបាន ?

៥) តើនរណាទាមទាសុំធ្វើជាទាសករជំនួសបេនយ៉ាមីន ?

៦) តើយ៉ូសែបឲ្យពួកគេធ្វើអ្វី ក្រោយពីប្រាប់ពួកគេថាគាត់ជានរណាហើយ ?

**ចម្លើយ**

១) ភារកិច្ចយ៉ូសែបគឺគ្រប់គ្រង ផ្ទុកស្បៀងអាហារ អំឡុងពេលភោគផលល្អ ដូចនេះនឹងមានស្បៀងគ្រប់គ្រាន់សម្រាប់ឆ្នាំដែលមិនមានភោគផលល្អ ។

២) លោកយ៉ាកុបឲ្យកូនកូនគាត់១០នាក់ទៅស្រុកអេស៊ីព្ទ ដើម្បីទិញស្បៀងអាហារ ។

៣) លោកយ៉ូសែបស្នើឲ្យបងៗរបស់គាត់ ទៅយកប្អូនពៅ បេនយ៉ាមីន មកស្រុកអេស៊ីព្ទ ។

៤) លោកយ៉ូសែបបានលាក់ពែងប្រាក់នៅក្នុងសម្ពាយរបស់បេនយ៉ាមីន ។

5) លោកយូដា បានសុំឲ្យយកគាត់ជាទាសករជំនួសបេនយ៉ាមីន ។

៦) ក្រោយពីលោកយ៉ូសែប បង្ហាញការពិតទាំងអស់ឲ្យពួកគេដឹង លោកបានឲ្យគេទៅផ្ទះ យកឪពុក និងក្រុមគ្រួសារទាំងអស់ ព្រមទាំងសត្វពួកគេមកស្រុកអេស៊ីព្ទ លោកនឹងរកកន្លែងល្អមួយសម្រាប់ទាំងអស់គ្នារស់នៅ ។


Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org